សម្រាប់ការចេញផ្សាយបន្ទាន់

# ក្រុមប្រឹក្សាជាន់ខ្ពស់នៃគណៈកម្មការទន្លេមេគង្គ អនុម័តលើយុទ្ធសាស្ត្រគ្រប់គ្រងគ្រោះរាំងស្ងួត និងគោលនយោបាយមួយចំនួនទៀតដើម្បីជួយលើកកម្ពស់សមត្ថភាពបណ្តាប្រទេសតាមដងទន្លេមេគង្គ ដើម្បីត្រៀមខ្លួនប្រឈមនឹងគ្រោះមហន្តរាយនាពេលអនាគត

**រាជធានីភ្នំពេញ ប្រទេសកម្ពុជា ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៩** – គណៈប្រតិភូជាន់ខ្ពស់របស់ក្រុមប្រឹក្សាគណៈកម្មការទន្លេមេគង្គ (ដែលហៅកាត់ថា MRC) បានអនុម័តលើយុទ្ធសាស្ត្រគ្រប់គ្រងគ្រោះរាំងស្ងួតសម្រាប់ឆ្នាំ ២០២០-២០២៥ នៅក្នុងជំនួបប្រចាំឆ្នាំនាថ្ងៃនេះ ក្នុងរាជធានីភ្នំពេញ ដើម្បីផ្តល់លទ្ធភាពឲ្យប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាមត្រៀមខ្លួម និងគ្រប់គ្រងគ្រោះរាំងស្ងួតរួមគ្នា។

យុទ្ធសាស្ត្រដែលបានអនុម័តនេះ បានធ្វើឡើងខណៈដែលតំបន់ទន្លេមេគង្គកំពុងជួបប្រទះគ្រោះរាំងស្ងួតធ្ងន់ធ្ងរមួយ ដែលបណ្តាលឲ្យកម្រិតទឹកទន្លេមេគង្គធ្លាក់ក្នុងកម្រិតទាបបំផុតនៅក្នុងប្រវត្តិសាស្ត្រ ឬក្នុងកំឡុងពេល៦០ឆ្នាំចុងក្រោយ។

ឯកឧត្តម លឹម គានហោ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាបានមានប្រសាសន៍ថា “ស្របពេលដែលយើងរៀបចំត្រៀមខ្លួនបង្ការនិងសម្រាលផលប៉ះពាល់នៃគ្រោះរាំងស្ងួត យុទ្ធសាស្ត្រនេះ នឹងជួយយើងកាត់បន្ថយនូវផលប៉ះពាល់ពីគ្រោះរាំងស្ងួតលើប្រជាជន និងប្រព័ន្ធធនធានទឹក ជួយអភិវឌ្ឍសមត្ថភាពក្នុងការសម្របខ្លួនរបស់រាជរដ្ឋាភិបាលយើង និងជួយជំរុញប្រព័ន្ធចែករំលែកព័ត៌មាន ព្យាករណ៍ និងប្រកាសអាសន្នឲ្យកាន់តែប្រសើរជាងមុន។” ។

ឯកឧត្តមរដ្ឋមន្ត្រី ដែលជាប្រធានក្រុមប្រឹក្សាគណៈកម្មការទន្លេមេគង្គសម្រាប់ឆ្នាំ២០១៩ បានបន្ថែមថាយុទ្ធសាស្ត្រនេះជាផ្នែកមួយនៃ“ការខិតខំប្រឹងប្រែងបន្តរបស់គណៈកម្មាការទន្លេមេគង្គ ដើម្បីគាំទ្រដល់បណ្តាប្រទេសជាសមាជិក ក្នុងការប្រយុទ្ធប្រឆាំងទៅនឹងគ្រោះរាំងស្ងួតនាពេលបច្ចុប្បន្ន និងក្នុងពេលអនាគត ដែលផ្តល់ផលប៉ះពាល់ទាំងនៅកម្រិតថ្នាក់ជាតិ និងឆ្លងដែន។”

តាមរយៈការសិក្សារបស់ MRC ថ្មីៗនេះបង្ហាញថា ប្រេកង់ និងកម្រិតធ្ងន់ធ្ងរនៃគ្រោះរាំងស្ងួតនៅក្នុងតំបន់អាងទន្លេមេគង្គក្រោមបានកើនឡើងនៅក្នុងកំឡុងពេលប៉ុន្មានទសវត្សន៍កន្លងមកនេះ។ ឧទាហរណ៍ គ្រោះរាំងស្ងួតចុងក្រោយបង្អស់ក្នុងឆ្នាំ២០១៦ បានធ្វើឲ្យសេដ្ឋកិច្ចប្រទេសថៃបាត់បង់ថវិកាអស់ប្រមាណជា ១.៧ពាន់លានដុល្លារ។

យុទ្ធសាស្ត្រនេះនឹងផ្តោតលើគោលដៅអាទិភាពទាំង៥ ដែលត្រូវបានគេវាយតម្លៃថា “មានដំណើរការមិនល្អ” និងត្រូវការ“ការយកចិត្តទុកដាក់ជាបន្ទាន់” ដើម្បីដោះស្រាយវិបត្តិគ្រោះរាំងស្ងួត។ យុទ្ធសាស្ត្រនេះរួមបញ្ចូលនូវសូចនាករពិនិត្យតាមដានស្ថានភាពដី សំណើមដី ស្ថានភាពដំណាំ និងលំហូរទឹក ក្នុងរដូវប្រាំង ព្រមទាំងការព្យាករណ៍គ្រោះរាំងស្ងួតនិងការប្រកាសអាសន្ន ការកសាងសមត្ថភាពរៀបចំផែនការនិងវាយតម្លៃស្ថានភាពគ្រោះរាំងស្ងួត ក៏ដូចជាវិធានការកាត់បន្ថយហានិភ័យ និងប្រព័ន្ធចែករំលែកព័ត៌មាន។

យុទ្ធសាស្ត្រ៥ឆ្នាំនេះនឹងត្រូវអនុវត្តដោយមានការគាំទ្រថវិកាពីបណ្តាប្រទេសជាសមាជិក និងដៃគូអភិវឌ្ឍន៍។

ក្រុមប្រឹក្សា ដែលជាស្ថាប័នថ្នាក់រដ្ឋមន្ត្រីខ្ពស់ជាងគេ នឹងមានសមាសភាពរដ្ឋមន្ត្រីពីក្រសួងធនធានទឹក និងបរិស្ថាន ពីបណ្តាប្រទេសជាសមាជិកទាំង៤ ក៏បានអនុម័តលើ ផែនការការងារប្រចាំឆ្នាំ២០២០-២០២១ ជាមួយនឹងកញ្ចប់ថវិកាចំនួនជាង១៣លានដុល្លារផងដែរ។ ផែនការនេះគឺជាផែនការលម្អិតលើប្រតិបត្តិការ សកម្មភាព និងកិច្ចការ រួមទាំងថវិកាពាក់ព័ន្ធក្នុងការអនុវត្តផែនការយុទ្ធសាស្ត្ររបស់ស្ថាប័ននៅក្នុងកម្រិតថ្នាក់តំបន់។

ផែនការដែលត្រូវបានអនុម័តនេះ ផ្តោតលើការបញ្ចប់នូវយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេថ្មីឆ្នាំ២០២១-២០៣០ និងផែនការយុទ្ធសាស្ត្រឆ្នាំ២០២១-២០២៥ ព្រមទាំងយុទ្ធសាស្ត្របរិស្ថានអាងទន្លេ សម្រាប់ការពារធនធាន បរិស្ថានសំខាន់ៗ។ ក្នុងចំណោមអាទិភាពជាច្រើន ផែនការនេះផ្តល់អាទិភាពលើការបញ្ចប់ដំណើរការពិគ្រោះយោបល់ជាមុនសម្រាប់គម្រោងសាងសង់ទំនប់វារីអគ្គិសនីលួងប្រាបាង ការអនុវត្តពិនិត្យតាមដានបរិស្ថានរួមគ្នាសម្រាប់ទំនប់មេ គ្រោះរាំងស្ងួត និងយុទ្ធសាស្ត្រវារីអគ្គិសនី ព្រមទាំងជំរុញភាពជាដៃគូជាមួយនឹងប្រទេសចិន និងកិច្ចសហប្រតិបត្តិការឡានឆាង-មេគង្គឲ្យកាន់តែប្រសើរ។

នៅក្នុងកិច្ចប្រជុំត្រៀមនាពេលម្សិលមិញ គណៈកម្មាធិការរួមដែលជាស្ថាប័នគ្រប់គ្រងរបស់ MRC បានផ្តល់ការគាំទ្រលើសៀវភៅអនុទ្ទេសហិរញ្ញវត្ថុថ្មី និងគោលគំនិតសម្រាប់ការរចនា ប្រព័ន្ធព្យាករណ៍ ប្រព័ន្ធម៉ូដែល ប្រព័ន្ធព័ត៌មាននិងទិន្នន័យរបស់ MRC។

សៀវភៅអនុទ្ទេសហិរញ្ញវត្ថុថ្មី ដែលជាសមិទ្ធផលពីបច្ចុប្បន្នភាពនៃសៀវភៅឆ្នាំ២០០៦ រៀបរាប់អំពីយន្តការរឹងមាំក្នុងការគ្រប់គ្រងកិច្ចការផ្ទៃក្នុង និងការគ្រប់គ្រងធនធានហិរញ្ញវត្ថុរបស់ស្ថាប័នឲ្យកាន់តែប្រសើរ ដើម្បីចូលរួមចំណែកក្នុងការកាត់បន្ថយហានិភ័យ ព្រមទាំងលើកកម្ពស់តម្លាភាព និងគណនេយ្យភាពក្នុងការគ្រប់គ្រងថវិកា។

គោលគំនិតសម្រាប់ការរចនាប្រព័ន្ធនានា គឺការខិតខំរបស់លេខាធិការដ្ឋាន MRC ដើម្បីស្តារឡើងវិញនូវប្រព័ន្ធព្យាករណ៍ ប្រព័ន្ធម៉ូដែល និងប្រព័ន្ធព័ត៌មាននិងទិន្នន័យរបស់ស្ថាប័ន។ គោលគំនិតនេះគ្រប់ដណ្តប់លើចំណុចការងារសំខាន់ៗចំនួន៤ ដើម្បីឆ្លើយតបនឹងបម្រែបម្រួលដែលកើតមានឲ្យបានរហ័សជាងមុន ដូចជា ការបញ្ចេញទឹកភ្លាមៗពីអាងស្តុកទឹកផ្នែកខាងលើ ក៏ដូចជាក្នុងគោលបំណងពិនិត្យតាមដាន

ការអភិវឌ្ឍ និងស្ថានភាពអាងទន្លេ ព្រមទាំងពង្រឹងតួនាទីដ៏សំខាន់មួយរបស់ MRC ក្នុងនាមជាមជ្ឈមណ្ឌលប្រមូលផ្តុំចំណេះដឹង។ កិច្ចការងារទាំងនេះរួមមានការប្រមូលនិងទិញទិន្នន័យ ការគ្រប់គ្រងព័ត៌មាន និងទិន្នន័យ ការវាយតម្លៃនិងវិភាគទិន្នន័យ ព្រមទាំងការទំនាក់ទំនងនិងធ្វើរបាយការណ៍អំពីព័ត៌មាន និងទិន្នន័យ។

កិច្ចប្រជុំរយៈពេល២ថ្ងៃនេះនឹងបញ្ចប់នៅថ្ងៃស្អែក។ ប្រទេសឡាវនឹងធ្វើជាម្ចាស់ផ្ទះនៅឆ្នាំក្រោយ ដោយហេតុថា ប្រទេសនេះនឹងក្លាយជាប្រធានក្រុមប្រឹក្សា MRC សម្រាប់ឆ្នាំ២០២០។

**កំណត់សម្គាល់សម្រាប់និពន្ធនាយកៈ**

គណៈកម្មការទន្លេមេគង្គ គឺជាស្ថាប័នអន្តររដ្ឋាភិបាល ដែលមានតួនាទីជំរុញលើកកម្ពស់កិច្ចពិគ្រោះយោបល់ និងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់នៅក្នុងតំបន់អាងទន្លេមេគង្គខ្សែទឹកខាងក្រោម ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៥ ផ្អែកទៅតាមកិច្ចព្រមព្រៀងទន្លេមេគង្គ រវាងប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម។ ស្ថាប័ននេះ បំពេញតួនាទីជាវេទិកាថ្នាក់តំបន់សម្រាប់ការទូតទឹក ក៏ដូចជា ជាមជ្ឈមណ្ឌលប្រមូលផ្តុំចំណេះដឹងអំពីការគ្រប់គ្រងធនធានទឹក ដើម្បីការអភិវឌ្ឍន៍តំបន់នេះ ប្រកបដោយចីរភាព។

**-ចប់-**

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងៈ**
លោក មាស សុភក្រ្ត
មន្រ្តីទំនាក់ទំនងជាមួយអ្នកសារព័ត៌មាន
លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ
អ៊ីម៉ែលៈ sopheak@mrcmekong.org
ទូរសព្ទដៃៈ +855 12 266653